4

# សន្ទឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ

# ការធ្វើទំនាក់ទំនងជាមួយអ្នកជិតខាង

ដើម្បីចៀសវាងការយល់ច្រឡំជាមួយអ្នកជិតខាងរបស់លោកអ្នក និងដើម្បីកាត់បន្ថយនូវការប្ដឹងតវ៉ា វាជាការមានប្រយោជន៏ដែលលោកអ្នកត្រូវជំរាបអ្នកជិតខាងរបស់លោកអ្នក អំពីសកម្មភាពទាំងឡាយដែលអាចប៉ះពាល់ដល់គេ។

អ្នកជិតខាងរបស់លោកអ្នកប្រហែលជាពុំមានប្រវត្តិកសិកម្ម ហេតុដូច្នេះហើយគេប្រហែលជាពុំសូវយល់ថាតើលោកអ្នកកំពុងធ្វើអ្វី ឬយល់អំពីមូលហេតុដែលលោកអ្នកកំពុងធ្វើ។ ដោយសារការជំរាបឲ្យគេបានដឹងអំពីគំរោងរបស់លោកអ្នក និងអំពីរយៈពេលដែលសកម្មភាពនោះត្រូវធ្វើឡើង លោកអ្នកនឹងកាត់បន្ថយនូវឱកាសដែលគេនឹងធ្វើការប្ដឹងតវ៉ា។

ខាងក្រោមនេះគឺជាសំណៅគំរូមួយដែលលោកអ្នកអាចយកប្រើ សំរាប់រៀងរាល់ពេលណាដែលលោកអ្នកមានគំរោងនឹងធ្វើអ្វីមួយ ដែលអាចប៉ះពាល់ដល់អ្នកជិតខាងរបស់លោកអ្នក។



NSW DPI, Virginia Brunton



NSW DPI, Steven Honeywood

**សន្ទឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ជូនចំពោះ (ដាក់បញ្ចូលឈ្មោះអ្នកជិតខាង)

ខ្ញុំសូមសរសេរលិខិតនេះជាកិច្ចគួរសមដើម្បីជំរាបលោកអ្នកឲ្យបានដឹងថា ជាផ្នែកនៃការអនុវត្តន៏កសិកម្មធម្មតា ខ្ញុំនឹង (ដាក់បញ្ចូលសកម្មភាព) សំរាប់រយៈពេល (ដាក់បញ្ចូលរយៈពេលដែលត្រូវការ)។

សកម្មភាពនេះនឹងចាប់ផ្ដើមនៅ (ដាក់បញ្ចូលថ្ងៃខែ និងពេលម៉ោង) ហើយនឹងត្រូវចប់នៅ (ដាក់បញ្ចូលថ្ងៃខែ និងពេលម៉ោង)។

ខ្ញុំសង្ឃឹម ហើយសូមអរគុណចំពោះការយោគយល់របស់លោកអ្នកនៅក្នុងអម្លុងពេលនេះ។ ប្រសិនបើលោកអ្នកមានសំណួរណាមួយ សូមទាក់ទងជាមួយខ្ញុំតាមទូរស័ព្ទលេខ (ដាក់បញ្ចូលលេខទូរស័ព្ទ)។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទទៅកិច្ចបំរើបកប្រែភាសាសរសេរ និងភាសានិយាយលេខ 131 450 (គេប្រហែលជាគិតថ្លៃចំពោះកិច្ចបំរើនេះ)។ ខ្ញុំចេះនិយាយភាសា (ដាក់បញ្ចូលភាសា)។

ដោយសេចក្ដីគោរព និងការរាប់អានអំពីខ្ញុំ

(ហត្ថលេខា និងសរសេរឈ្មោះរបស់លោកអ្នក)

## សកម្មភាពកសិកម្មជាទូទៅ

| | |
|---|---|
| ការបាញ់ថ្នាំសម្លាប់សត្វចង្រៃ | ការកំចាត់រុក្ខជាតិតូចៗឥតប្រយោជន៏ |
| ការភ្ជួររាស់ | ការដាក់ប្រព័ន្ធបង្ហូរទឹក |
| ការដកស្ទូង | ការប្រមូលផល |
| ការដាក់ជីនៅតាមចំការ | ការកាប់ដើមឈើចេញដោយមានការអនុញ្ញាតពីសាលាក្រុង |

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្ដី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្ដីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST